ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# សេចក្តីប្រកាសព័ត៌មាន

ក្រុមការងារដោះស្រាយវិវាទដីសម្បទានសេដ្ឋកិច្ចដំណាំអំពៅផលិតស្ករសនាំចេញ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានទទួលបំពេញសលាកបត្រព័ត៌មាន ចាប់ពីថ្ងៃទី ០៤ ខែកញ្ញា ដល់ថ្ងៃទី ០៣ ខែតុលា ឆ្នាំ ២០១៧ ចំនួន ៨៧ ករណី ពាក់ព័ន្ធនឹងក្រុមហ៊ុនចំនួន ០៥ គឺក្រុមហ៊ុន ឡាន ហ្វេង (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធីត, ក្រុមហ៊ុន រូយ ហ្វេង (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធីត, ក្រុមហ៊ុន ហេងយូ (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធីត, ក្រុមហ៊ុន ហេង រូយ (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធីត និងក្រុមហ៊ុន ហេង ណុង (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធីត នៅក្នុងភូមិសាស្ត្រស្រុកត្បែងមានជ័យ ស្រុកឆែប និងស្រុកជ័យសែន ខេត្តព្រះវិហារ។

គិតត្រឹមថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០១៧ នេះ ក្រុមការងារសម្រេចលទ្ធផលដូចខាងក្រោម÷

- ប្រជាពលរដ្ឋបានទទួលការដោះស្រាយរួចចំនួន ៦៣ ករណី
- បន្តដោះស្រាយករណីនៅសល់ចំនួន ០៩ ករណី ក្នុងនោះ នៅស្រុកឆែប ០៦ ករណី និង ស្រុកជ័យសែន ចំនួន ០៣ ករណី
- ទុកដោះស្រាយតាមយន្តការសម្បទានដីសង្គមកិច្ចចំនួន ១៥ ករណី នៅស្រុកត្បែងមានជ័យ។

អាស្រ័យហេតុនេះ សូមបងប្អូនប្រជាពលរដ្ឋនិងសាធារណជនមេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃសុក្រ ១២កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០១៧